# ឧត្តមភាពសិក្សា

## លទ្ធផលសិក្សាវិទ្យាល័យ WESLEY ឆ្នាំ2024

និស្សិតអន្តរជាតិ



WESLEY COLLEGE

MELBOURNE AUSTRALIA · SINCE 1866

# ការសម្តែងនូវការកោតសរសើរ ចំពោះនិស្សិតបញ្ចប់ការសិក្សាឆ្នាំ2024

## យើងមានមោទនភាព ហើយសូមសម្តែងនូវការកោតសរសើរយ៉ាងក្រៃលែង និងអបអរសាទរចំពោះសមិទ្ធផលនិស្សិតថ្នាក់ទី12 VCE និង IB DP ឆ្នាំ2024 របស់យើង។

យុវជនគួរឱ្យចាប់អារម្មណ៍ទាំងនេះបានបង្ហាញពីស្នាដៃដ៏ឆ្នើម ភាពធន់ និងចំណង់ចំណូលចិត្តយ៉ាងជ្រាលជ្រៅក្នុងការរៀនសូត្រ។ រឿងផ្ទាល់ខ្លួនរបស់ពួកគេបង្ហាញពីការរីកចម្រើនផ្ទាល់ខ្លួន និងការសិក្សារបស់ពួកគេបង្ហាញពីភាពក្លាហាន ការចង់ដឹងចង់ឃើញ និងការប្តេជ្ញាចិត្តចំពោះឧត្តមភាពលើគ្រប់វិស័យនៃការខិតខំប្រឹងប្រែង។

មិនថានៅក្នុងថ្នាក់រៀន លើវិស័យកីឡា តាមរយៈតន្ត្រី និងសិល្បៈ ក្នុងភាពជាអ្នកដឹកនាំ ឬក្នុងការបម្រើសហគមន៍នោះទេ និស្សិតបញ្ចប់ការសិក្សាឆ្នាំ2024 បានចាប់យករាល់ឱកាសដើម្បីប្រកួតប្រជែងខ្លួនឯង និងធ្វើឱ្យមានផលប៉ះពាល់ដ៏មានអត្ថន័យ។ ការរួមចំណែករបស់ពួកគេបានលើកស្ទួយសហគមន៍វិទ្យាល័យ Wesley ហើយយើងដឹងថាពួកគេនឹងនាំយកស្មារតីដូចគ្នានេះ ឆ្ពោះទៅកាន់ពិភពលោកលើសពីច្រកទ្វាររបស់យើង។

ក្នុងនាមជាសាលាអប់រំឈានមុខគេដែលបើកចំហការសិក្សាសម្រាប់សិស្សប្រុសស្រីរួមគ្នា យើងពិតជាមានមោទនភាពយ៉ាងខ្លាំងមិនត្រឹមតែចំពោះសមិទ្ធផលសិក្សារបស់និស្សិតយើងប៉ុណ្ណោះទេ ប៉ុន្តែនៅក្នុងនិស្សិតម្នាក់ៗដែលពួកគេក្លាយជាបុគ្គលដែលមានជំនាញ បទពិសោធន៍ និងសមត្ថភាពផ្សេងៗគ្នា។ ខណៈពេលដែលការខិតខំប្រឹងប្រែងរបស់ពួកគេនឹងទទួលបានឱកាសល្អៗ វាគឺជាចរិតលក្ខណៈ ចិត្តសប្បុរស និងការប្តេជ្ញាចិត្តរបស់ពួកគេ ដែលនឹងកំណត់ភាពជោគជ័យនាពេលអនាគតរបស់ពួកគេ។

ខ្ញុំសូមទទួលស្គាល់ផងដែរនូវការលះបង់របស់បុគ្គលិកបង្រៀនពិសេសរបស់យើង ជាពិសេសបុគ្គលិកកម្មវិធីត្រៀមភាសាអង់គ្លេសរបស់យើង អ្នកសម្របសម្រួលនិស្សិតអន្តរជាតិ និងបុគ្គលិកសាលាជាន់ខ្ពស់ - ដែលបានដឹកនាំ និងគាំទ្រនិស្សិតអន្តរជាតិរបស់យើងពេញទូទាំងការធ្វើដំណើររបស់ពួកគេនៅវិទ្យាល័យ Wesley។

នៅឆ្នាំ2024 យើងបានស្វាគមន៍និស្សិតអន្តរជាតិមកពីប្រទេសចិន វៀតណាម ឥណ្ឌូនេស៊ី ម៉ាឡេស៊ី សិង្ហបុរី ថៃ និងកូរ៉េនៅទូទាំងវិទ្យាល័យ។ ក្រុមនេះបំពេញការសិក្សាបានល្អជាពិសេស ដោយសម្រេចបាន ATAR 90.65 ជាមធ្យម។ អ្នកដែលបានបញ្ចប់ VCE ទទួលបាន ATAR 94.80 មធ្យមដ៏ឆ្នើម។ សេចក្តីប្រាថ្នារបស់ពួកគេឆ្លុះបញ្ចាំងពីចំណាប់អារម្មណ៍ចម្រុះ ដោយមាននិស្សិតនានាគ្រោងនឹងបន្តការសិក្សាក្នុងវិស័យវិទ្យាសាស្ត្រ បច្ចេកវិទ្យាព័ត៌មាន ពាណិជ្ជកម្ម សុខភាព អាជីវកម្ម សិល្បៈ និងសិល្បៈច្នៃប្រឌិត។ និស្សិតជាច្រើនបានដាក់ពាក្យទៅសាកលវិទ្យាល័យកំពូលៗរបស់ទីក្រុងមែលប៊ន ខណៈពេលដែលនិស្សិតផ្សេងទៀតកំពុងរង់ចាំការផ្តល់ជូនកន្លែងសិក្សាពីស្ថាប័ននានានៅក្រៅប្រទេស។ គួរឱ្យចាប់អារម្មណ៍ 100% នៃនិស្សិតបញ្ចប់ការសិក្សាឆ្នាំ2024 បានទទួលការផ្តល់ជូនកន្លែងសិក្សានៅឧត្តមសិក្សាជុំទីមួយ។

សូមអបអរសាទរដល់និស្សិតបញ្ចប់ការសិក្សាឆ្នាំ2024 ចំពោះអ្វីទាំងអស់ដែលអ្នកបានសម្រេច។ អ្នកបានបន្សល់ទុកនូវមរតកនៃការតស៊ូ ក្តីមេត្តា និងមហិច្ឆិតា ហើយនឹងមិនមានការងឿងឆ្ងល់ថានឹងបន្តសម្រេចបាននូវអ្វីដែលអស្ចារ្យនោះទេ។ នៅពេលអ្នកចាប់ផ្តើមវគ្គបន្ទាប់នេះ យើងសូមជូនពរឱ្យអ្នកទទួលបានជោគជ័យ និងសម្រេចបានអ្វីៗគ្រប់យ៉ាងនៅក្នុងដំណើរដ៏គួរឱ្យរំភើបនាពេលខាងមុខ។

មើលនិស្សិតបញ្ចប់ការសិក្សាឆ្នាំ2024 ឆ្លុះបញ្ចាំងពីសមិទ្ធផលរបស់ពួកគេ



**Nick Evans**
នាយកវិទ្យាល័យ

# លទ្ធផលសិក្សា និស្សិតបញ្ចប់ការសិក្សាឆ្នាំ2024

ក្នុងឆ្នាំ2024 និស្សិត 372 នាក់បានបញ្ចប់ការសិក្សាថ្នាក់ទី12 របស់ពួកគេ រួមទាំងនិស្សិតអន្តរជាតិចំនួន 15 នាក់។ 60% បានសិក្សា VCE និង 40% បានសិក្សាកម្មវិធីវិញ្ញាបនបត្រសិក្សាទុតិយភូមិអន្តរជាតិ (IB DP)។

## ការប្រៀបធៀប ATAR ឆ្នាំ2024







13% នៃនិស្សិតសម្រេចបាន **ATAR 95** ឬខ្ពស់ជាង




33% នៃនិស្សិតសម្រេចបាន ATAR 90 ឡើងទៅ ហើយដាក់ពួកគេស្ថិតក្នុងលំដាប់កំពូល **10%** ក្នុងប្រទេសអូស្ត្រាលី




60% នៃនិស្សិតសម្រេចបាន ATAR 80 ឡើងទៅ ហើយដាក់ពួកគេស្ថិតក្នុងលំដាប់កំពូល **20%** ក្នុងប្រទេសអូស្ត្រាលី

និស្សិតអន្តរជាតិ
ATAR VCE និង IB DP មធ្យមរួមបញ្ចូលគ្នា
**90.65**

និស្សិតទាំងអស់
ATAR VCE និង IB DP មធ្យមរួមបញ្ចូលគ្នា
**83.85**

និស្សិតអន្តរជាតិ
**VCE ATAR** មធ្យម
**94.80**

និស្សិតអន្តរជាតិ
**IB DP ATAR** មធ្យម
**89.90**

**100%**

100% នៃនិស្សិត VCE និង IB DP បានទទួលការផ្តល់ជូនកន្លែងសិក្សាកម្រិតឧត្តមសិក្សាជុំទីមួយ

ពិន្ទុមធ្យមមុខវិជ្ជា IB DP នៅវិទ្យាល័យ Wesley
**35.00**

ពិន្ទុមធ្យមមុខវិជ្ជា IB DP ទូទៅ
**29.00**

**128**

ការសិក្សា VCE និងមុខវិជ្ជាដែលបានពិន្ទុ IB DP ដ៏ល្អឥតខ្ចោះ

## ប្រធានវិទ្យាល័យ

**Joseph Chen**
IB DP, 99.95

**Dominic Wang**
VCE, 99.80

**Emily Walsh**
IB DP, 99.40

**Hannah Manne**
VCE, 98.85

ATAR
**99+**
x9

**ការសម្តែងនូវសេចក្តីសរសើរ**ចំពោះនិស្សិតប្រាំបួននាក់ដែលសម្រេចបាន ATAR 99 ឬខ្ពស់ជាងនេះ ដោយដាក់ពួកគេស្ថិតក្នុងលំដាប់**កំពូល 1%**

**មុខវិជ្ជាដែលបានពិន្ទុល្អឥតខ្ចោះ**
**7**
**IB DP**

ជីវវិទ្យា
ការគ្រប់គ្រងអាជីវកម្ម
គីមីវិទ្យា
ភាសាចិន B
បច្ចេកវិទ្យារចនា
ភាសាហូឡង់ AB
សេដ្ឋកិច្ច
ភាសាអង់គ្លេស និងអក្សរសាស្ត្រ
ភាសាអង់គ្លេស B
ភាពយន្ត
ភាសាបារាំង B
ភូមិវិទ្យា
ភាសាអាឡឺម៉ង់
ភាសាអ៊ីតាលី AB
ការវិភាគ និងវិធីសាស្ត្រគណិតវិទ្យា
ការអនុវត្តន៍ និងការបកស្រាយគណិតវិទ្យា
តន្ត្រី
រូបវិទ្យា
ចិត្តវិទ្យា
ភាសាអេស្បាញ AB
ភាសាអេស្ប៉ាញ B
លំហាត់កីឡា វិទ្យាសាស្ត្រសុខភាព
សិល្បៈដែលមើលឃើញ

**ពិន្ទុសិក្សាលើសពី**
**45**
**VCE**

ជីវវិទ្យា
ការគ្រប់គ្រងអាជីវកម្ម
គីមីវិទ្យា
ភាសាអង់គ្លេស
ភូមិវិទ្យា
ការសិក្សាផ្នែកច្បាប់
គណិតវិទ្យាទូទៅ
វិធីសាស្ត្រគណិតវិទ្យា
ឯកទេសគណិតវិទ្យា
ការទំនាក់ទំនងផ្នែកប្រព័ន្ធផ្សព្វផ្សាយ
ការរចនាផលិតផល និងបច្ចេកវិទ្យា
ចិត្តវិទ្យា

* ATARs មួយចំនួនមិនបានបោះពុម្ពនៅក្នុងកូនសៀវភៅនេះទេ ដោយពិចារណាលើសំណើរបស់និស្សិត។

# គោលដៅ

100% នៃនិស្សិតថ្នាក់ទី12 របស់យើង បានទទួលការផ្តល់ជូនកន្លែងសិក្សាដែលជាជម្រើសទីមួយ ពីសាកលវិទ្យាល័យកំពូលនៃទីក្រុងមែលបិន។ 56% នៃនិស្សិតបានទទួលយកការផ្តល់ជូនកន្លែងសិក្សាពីសាកលវិទ្យាល័យមែលបិន និងសាកលវិទ្យាល័យម៉ូណាស្ហ ដោយឆ្លុះបញ្ចាំងពីស្តង់ដារសិក្សាខ្ពស់នៃការបង្រៀន និងការរៀនសូត្រនៅវិទ្យាល័យ។

សេចក្តីប្រាថ្នានៃនិស្សិតរបស់យើងមិនកំណត់ចំពោះប្រទេសអូស្ត្រាលីទេ មានខ្លះបានជ្រើសរើសដាក់ពាក្យទៅសិក្សានៅសាកលវិទ្យាល័យនៅបរទេស។ និស្សិតទាំងនេះមួយចំនួនបានទទួលការផ្តល់ជូនកន្លែងសិក្សារួចហើយ រួមមានកន្លែងម្នាក់នៅមហាវិទ្យាល័យ New College, សាកលវិទ្យាល័យ Oxford, ម្នាក់កន្លែងនៅសាកលវិទ្យាល័យ Michigan និងម្នាក់ទៀតនៅមហាវិទ្យាល័យ Jesus College, Cambridge។

ក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះ និស្សិតបញ្ចប់ការសិក្សា Wesley បានទទួលយកកន្លែងសិក្សានានានៅសាកលវិទ្យាល័យអន្តរជាតិកំពូលៗជាច្រើន រួមមាន៖

**ចក្រភពអង់គ្លេស**

សាកលវិទ្យាល័យ Cambridge
សាកលវិទ្យាល័យ Oxford
សាកលវិទ្យាល័យ Edinburgh
សាកលវិទ្យាល័យ Warwick
មហាវិទ្យាល័យ King's College London
មហាវិទ្យាល័យ Imperial ទីក្រុងឡុងដ៍

**សហរដ្ឋអាមេរិក**

សាកលវិទ្យាល័យ Penn State
សាកលវិទ្យាល័យតិចសាស់
សាកលវិទ្យាល័យកាលីហ្វ័រញ៉ា Berkeley
សាកលវិទ្យាល័យ Michigan




# វិស័យសិក្សា

និស្សិតបញ្ចប់ការសិក្សាឆ្នាំ2024 កំពុងបន្តការសិក្សាបន្ថែមទៀតនៅក្នុងវិស័យចម្រុះ ដែលឆ្លុះបញ្ចាំងពីទេពកោសល្យ ចំណាប់អារម្មណ៍ និងសមត្ថភាពពិសេសរបស់ពួកគេ។



# និស្សិតបញ្ចប់ការសិក្សារបស់យើង



## Emily Walsh

**ប្រធានក្រុម IB DP, ATAR 99.40**

IB DP មានភាពស័ក្តិសមជាធម្មតាសម្រាប់ខ្ញុំ ដោយសារខ្ញុំចូលចិត្តមុខវិជ្ជាផ្សេងៗ មានចំណាប់អារម្មណ៍ចម្រុះ និងចូលចិត្តការប្រជែងក្នុងការសិក្សា។ ខ្ញុំមានគម្រោងបន្តទទួលយកវិធីសាស្ត្រពហុជំនាញចំពោះការសិក្សារបស់ខ្ញុំ ដោយបន្តការសិក្សាថ្នាក់បរិញ្ញាបត្រទ្វេផ្នែកជីវវេជ្ជសាស្ត្រ និងច្បាប់។ ក្តីសង្ឃឹមរបស់ខ្ញុំគឺដើម្បីកសាងអាជីពដែលរួមបញ្ចូលគ្នានូវ STEM និងច្បាប់ ដោយដោះស្រាយបញ្ហាស្មុគស្មាញដែលវិទ្យាសាស្ត្រ និងគោលនយោបាយប្រសព្វគ្នា។ ខ្ញុំរំភើបក្នុងការស្វែងយល់ពីរបៀបដែលវិស័យទាំងពីរនេះអាចធ្វើការជាមួយគ្នា ដើម្បីបង្កើតការផ្លាស់ប្តូរប្រកបដោយអត្ថន័យ និងរួមចំណែកដល់សង្គម។



## Hannah Manne

**ប្រធានក្រុម VCE, ATAR 98.85**

ទោះបីថ្នាក់ទី12 ជាឆ្នាំដ៏លំបាកក៏ដោយ ប៉ុន្តែមកដល់ពេលនេះ វាផ្តល់ឱ្យខ្ញុំនូវអារម្មណ៍នៃការពេញចិត្តយ៉ាងខ្លាំង ហើយខ្ញុំមានអារម្មណ៍ថាមានភាពជាម្ចាស់ដ៏អស្ចារ្យ។ អន្តរកម្មដែលខ្ញុំធ្លាប់មាន និងមិត្តភាពដែលខ្ញុំបានបង្កើតនៅក្នុងបរិយាកាសសិក្សារបស់វិទ្យាល័យ Wesley បានរៀបចំខ្ញុំយ៉ាងពិតប្រាកដសម្រាប់ពិភពពិតនេះ។ ការនេះធ្វើឱ្យខ្ញុំមានទំនុកចិត្តនៅពេលខ្ញុំទៅសាកលវិទ្យាល័យ និងចូលរួមក្នុងកម្លាំងពលកម្ម។ ឆ្នាំក្រោយ ខ្ញុំចង់សិក្សាបរិញ្ញាបត្រពាណិជ្ជកម្មនៅសាកលវិទ្យាល័យមែលបិន រួមជាមួយនឹងសញ្ញាប័ត្រភាសាបារាំង ព្រោះខ្ញុំមានបទពិសោធន៍វិជ្ជមាន និងសម្បូរបែបក្នុងការសិក្សាភាសាបារាំង។



## Kelly Cheung

**VCE, ATAR 97.75**

តុល្យភាពពេលវេលារវាងការងារសាលា សកម្មភាពក្រៅកម្មវិធីសិក្សា និងពេលទំនេរផ្ទាល់ខ្លួនមានសារៈសំខាន់ណាស់សម្រាប់សុខុមាលភាព និងភាពជោគជ័យរបស់ខ្ញុំនៅថ្នាក់ទី12។ ការរក្សារបៀបរៀបរយ និងមានភាពបត់បែនបានអនុញ្ញាតឱ្យខ្ញុំរក្សាកម្រិតស្ត្រេសក្នុងការត្រួតពិនិត្យ និងបន្តដំណើរទៅមុខទៀត។ បរិយាកាសគាំទ្រនៅវិទ្យាល័យ Wesley បានធ្វើឱ្យថ្នាក់ទី12 កាន់តែងាយស្រួលសម្រាប់ខ្ញុំ។ ខ្ញុំពិតជាមានអំណរគុណចំពោះគ្រូបង្រៀនរបស់ខ្ញុំទាំងអស់ ចំពោការខិតខំប្រឹងប្រែងដ៏ជាប់លាប់របស់ពួកគេ ដែលមានសារៈសំខាន់សម្រាប់ភាពជោគជ័យក្នុងការសិក្សារបស់ខ្ញុំ។ នៅពេលណាដែលខ្ញុំប្រឈមនឹងបញ្ហានានា ខ្ញុំមានអារម្មណ៍សុខស្រួលក្នុងការទាក់ទងពួកគ្រូៗ ឬមិត្តរួមថ្នាក់របស់ខ្ញុំសម្រាប់ជំនួយ។ ដោយសម្លឹងឆ្ពោះទៅអនាគត ខ្ញុំសង្ឃឹមថានឹងសិក្សាវិទ្យាសាស្ត្រទិន្នន័យនៅសាកលវិទ្យាល័យ។



## Ryan Jackson

**VCE, ATAR 93.45**

ថ្នាក់ទី12 គឺជាឆ្នាំដ៏ល្អបំផុតមួយនៃជីវិតរបស់ខ្ញុំ។ អនុស្សាវរីយ៍ដ៏គួរឱ្យចាប់ចិត្តរបស់ខ្ញុំខ្លះ ពីពេលវេលានៅវិទ្យាល័យ Wesley គឺចាប់ពីប៉ុន្មានសប្តាហ៍ឈានដល់ការបញ្ចប់ការសិក្សា។ មិនថាដោយសារតែការសិក្សារយៈពេល 13 ឆ្នាំបានឈានចូលដល់ទីបញ្ចប់ ឬភាពតានតឹងរួមគ្នានៃការប្រឡងនោះទេ ពេលវេលាទាំងនោះបានអនុញ្ញាតឱ្យយើងឆ្លុះបញ្ចាំងយ៉ាងស៊ីជម្រៅអំពីមិត្តភាព និងទំនាក់ទំនងរបស់យើង។ យើងមិនត្រឹមតែកោតសរសើរចំពោះទំនាក់ទំនងដែលយើងចែករំលែកជាមួយគ្នាទៅវិញទៅមកប៉ុណ្ណោះទេ យើងទទួលស្គាល់ពីផលប៉ះពាល់យ៉ាងសំខាន់ដែលគ្រូបង្រៀនរបស់យើងមានលើជីវិតរបស់យើងផងដែរ។



## Dominic Wang

**ប្រធានក្រុម VCE, ATAR 99.80**

ក្នុងនាមជានិស្សិតរស់នៅតាមសាលាដែលផ្តល់កន្លែងស្នាក់នៅ និងអាហារបុគ្គលិក Learning in Residence បានផ្តល់បរិយាកាសរស់នៅដ៏អស្ចារ្យដែលមិនមានការរំខាន ដែលអនុញ្ញាតឱ្យខ្ញុំផ្តោតទៅលើអ្វីដែលខ្ញុំត្រូវធ្វើ។ នៅពេលណាដែលខ្ញុំត្រូវការជំនួយ ពួកគេតែងតែនៅទីនោះដើម្បីជួយខ្ញុំ។ នៅក្នុងបរិយាកាសអប់រំ មិត្តភក្តិរបស់ខ្ញុំ និងខ្ញុំបានរៀនគោរព យល់ចិត្ត និងគាំទ្រគ្នាទៅវិញទៅមក។ វាបានបង្រៀនខ្ញុំឱ្យផ្តល់តម្លៃលើភាពពិសេសរបស់ខ្លួនខ្ញុំព្រមទាំងទទួលស្គាល់ និងអបអរសមិទ្ធផលចម្រុះរបស់អ្នកដទៃ។



## Zi Yu Song

**IB DP, ATAR 99.60**

ក្នុងនាមជាប្រធានក្រុមថ្នាក់សាលាជាន់ខ្ពស់ បទពិសោធន៍ដ៏គួរឱ្យចងចាំបំផុតមួយចំនួនរបស់ខ្ញុំនៅវិទ្យាល័យ Wesley បានដឹកនាំក្រុមថ្នាក់របស់ខ្ញុំទៅកាន់ជ័យជំនះក្នុងកីឡាហែលទឹក អត្តពលកម្មប្រចាំក្រុមថ្នាក់ ហើយជាចុងក្រោយបានឈ្នះពានរង្វាន់ House Cup។ បទពិសោធន៍ទាំងនេះបានបង្រៀនខ្ញុំនូវជំនាញជាច្រើនក្នុងភាពជាអ្នកដឹកនាំ ការសហការ ការប្រាស្រ័យទាក់ទង និងការចាត់ចែងខណៈពេលដែលអនុញ្ញាតឱ្យខ្ញុំរៀនអំពីគុណសម្បត្តិដែលមានក្នុងអ្នកដទៃ និងស្វែងយល់ពីអ្វីដែលខ្ញុំពេញចិត្ត។ ការហែលទឹកគឺជាជំនាញរបស់ខ្ញុំ ហើយពេញទូទាំងថ្នាក់ទី12 វាបានបន្ធូរបន្ថយកម្រិតស្ត្រេសរបស់ខ្ញុំ និងអនុញ្ញាតឱ្យគំនិតរបស់ខ្ញុំបានសម្រាក ហើយស្តារឡើងវិញពីការរៀនសូត្រដ៏ខ្លាំងក្លាដែលខ្ញុំកំពុងធ្វើជារៀងរាល់ថ្ងៃ។



## Roman Smith

**IB DP, ATAR 99.15**

ការផ្តល់កន្លែងស្នាក់នៅ និងអាហាររបស់វិទ្យាល័យ Wesley គឺជាបទពិសោធន៍ដ៏ល្អសម្រាប់ខ្ញុំ។ ខ្ញុំអាចបង្កើតគ្រួសារទីពីរដែលមានចំណងមិត្តភាពដ៏មានន័យដែលខ្ញុំរំពឹងទុកថានឹងស្ថិតស្ថេរយូរជាងឆ្នាំរបស់យើងនៅ Wesley។ ការគាំទ្រដោយមិនងាករេពីបុគ្គលិកគឺមិនចាញ់អ្នកណាឡើយ ហើយខ្ញុំសូមអរគុណពួកគេចំពោះរឿងនោះ។ ក្នុងអំឡុងពេលដែលមានការលំបាកក្នុងឆ្នាំនេះ ខ្ញុំបានងាកទៅរកមិត្តភក្តិរបស់ខ្ញុំសម្រាប់ការគាំទ្រ។ ការចែករំលែកកំណត់ចំណាំ និងធនធានការចូលរួមក្រុម និងការពិភាក្សាបានជំរុញឱ្យមានស្មារតីរឹងមាំជាសហគមន៍ក្នុងចំណោមនិស្សិត IB DP ដែលបានជួយយើងក្នុងការធ្វើដំណើររបស់យើង។



## Lillian Rebelo

**IB DP**

ក្នុងចំណោមចំណុចសំខាន់ៗទាំងអស់របស់វិទ្យាល័យ Wesley ខ្ញុំពិតជាមានអំណរគុណបំផុតចំពោះគ្រូៗរបស់ខ្ញុំ ពួកគេបានខិតខំប្រឹងប្រែងយ៉ាងខ្លាំងក្នុងការជួយពួកយើងឱ្យក្លាយជាមនុស្សល្អបំផុត ក៏ដូចជាភាពសប្បុរស និងការចូលរួមផងដែរ។ ជាលទ្ធផល ខ្ញុំពិតជាចូលចិត្តរៀននៅវិទ្យាល័យ Wesley ណាស់! នៅថ្នាក់ទី12 ខ្ញុំបានធ្វើដំណើរកម្សាន្តផ្នែកភាសារបស់ Wesley ទៅកាន់ប្រទេសចិន ដែលជាឱកាសដ៏អស្ចារ្យមួយក្នុងការហាត់រៀនភាសាចិន និងស្វែងយល់ពីប្រវត្តិសាស្ត្រ និងវប្បធម៌នៃកន្លែងដ៏ស្រស់ស្អាត និងប្លែកពីគេ។ ខ្ញុំក៏មានសំណាងផងដែរដែលបានចូលរួមក្នុងកម្មវិធីតន្ត្រីរបស់វិទ្យាល័យ Wesley ដូចជាការលេងខ្លុយ និងត្រែបារាំងនៅក្នុងក្រុមតន្ត្រី និងវង់តន្ត្រី ដែលជួយធ្វើឱ្យខ្ញុំផ្តោតលើអ្វីដែលសំខាន់នៅពេលដែលមានកិច្ចមមារញឹក។

**Elsternwick**
5 Gladstone Parade
Elsternwick Victoria 3185
elsternwick@wesleycollege.edu.au

**Glen Waverley**
620 High Street Road
Glen Waverley Victoria 3150
gw@wesleycollege.edu.au

**St Kilda Road**
577 St Kilda Road
Melbourne Victoria 3004
stkildaroad@wesleycollege.edu.au

wesleycollege.edu.au
ទូរសព្ទ៖ + 61 3 8102 6888
ABN 55 611 238 530 CRICOS 00354G

បោះពុម្ពលើក្រដាសកែច្នៃ 100%

# ឧត្តមភាពសិក្សា

## លទ្ធផលសិក្សាវិទ្យាល័យ WESLEY ឆ្នាំ2024

និស្សិតអន្តរជាតិ

WESLEY COLLEGE
MELBOURNE AUSTRALIA - SINCE 1866